ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម
មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ

# សេចក្តីជូនដំណឹង
# អំពី
# ស្ថានភាពអាកាសធាតុរាជធានីភ្នំពេញ

**មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ** សូមគោរពជម្រាបជូនជាព័ត៌មានធាតុអាកាស ចាប់ពីថ្ងៃទី២៦ ខែមីនា ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ ខាងមុខនេះ៖

នឹងមានស្ថានភាពរលកកម្តៅប៉ះពាល់ដល់រាជធានីភ្នំពេញ។ ក្នុងអំឡុងពេលនេះ សីតុណ្ហភាពអតិបរមា ត្រូវបានព្យាករណ៍ថានឹងឈានដល់ចន្លោះពី ៣៧°C ដល់ ៤១°C ដែលខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ ស្ថានភាពរលកកម្តៅនេះកើតឡើងដោយសារកម្រិតសម្ពាធខ្ពស់ថេរ និងលំហូរខ្យល់ខ្សោយ បណ្តាលឲ្យមានកម្តៅខ្លាំងនៅបន្ត។

អាស្រ័យដូចបានជម្រាបជូន មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ សូមជូនដំណឹងជាសាធារណៈ សូមមេត្តាយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នអំពីអាកាសធាតុប្រែប្រួល មានស្ថានភាពរលកកម្តៅនេះ ដើម្បីជៀសវាងពីជំងឺដង្កាត់ផ្សេងៗ ដែលអាចកើតមានជាយថាហេតុលើមនុស្ស សត្វ រុក្ខជាតិ និងពិសេសយកចិត្តទុកដាក់ថែរទាំសុខភាពលើមនុស្សចាស់ ស្ត្រី និងកុមារ។

**មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ** នឹងបន្តការតាមដានសភាពការណ៍អាកាសធាតុ និងជម្រាបជូនជាបន្តបន្ទាប់ ក្នុងករណីមានការប្រែប្រួល។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦
**មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ**